ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ...៤៥.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យុទ្ធជនពិការ និងអតីតយុទ្ធជន

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា ១ : ផ្តល់ប្រាក់បំណាច់ជីវភាពចំនួន ពីរម៉ឺន (២០.០០០) រៀល ក្នុងមួយខែ ជូនមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យុទ្ធជនពិការ និង

www.pheakdeylaw.com

អតីតយុទ្ធជន លើកលែងតែមន្ត្រីដែលទទួលប្រាក់បំណាច់មុខងារនយោបាយ ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើង ។

មាត្រា ២ : ចំពោះមន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ជីវភាព ត្រូវបញ្ចូលទៅក្នុងតារាងទូទាត់បៀវត្សរ៍តាមប្រព័ន្ធព័ត៌មានវិទ្យាដូចប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិលដែរ ។ ចំពោះកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និវត្តន៍ជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យុទ្ធជនពិការ និងអតីតយុទ្ធជន ការបើកផ្តល់ប្រាក់បំណាច់ជីវភាព ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រសួង ស្ថាប័ន សាមីអង្គភាពនោះ ។

មាត្រា ៣ : ប្រាក់បំណាច់ជីវភាពដូចបានកំណត់ក្នុងមាត្រា ១ ខាងលើត្រូវអនុវត្តចាប់ពីខែ មករា ដល់ខែ ធ្នូ ឆ្នាំ២០០៩ ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com